**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣✵៣

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

លេខ ២៥៧ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៨

# ប្រកាស

## ស្ដីពី

## ការបង្កើតការិយាល័យអធិការកិច្ចការថែទាំជំនួសចំពោះកុមារ ស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានសុខុមាលភាពកុមារ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកម /០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្ដីពី ការតែងតាំងរាជ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១០៥ / ០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើ ច្បាប់ស្ដីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញប្រកាសលេខ ១០៥ សកបយ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០០៤ ស្ដីពីការបង្កើតគណៈកម្មាធិការប្រឹក្សាការ ថែទាំជំនួសចំពោះកុមារ
- បានឃើញប្រកាសលេខ ២១៧ សអយ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៦ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ស្ដីពីការដាក់ឱ្យអនុវត្តគោលនយោបាយស្ដីពីការថែទាំជំនួសចំពោះកុមារ
- បានឃើញប្រកាសលេខ ៦១៦ សអយ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៦ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ស្ដីពីបទដ្ឋានអប្បបរមាសំរាប់ការថែទាំជំនួសចំពោះកុមារក្នុងមណ្ឌល
- បានឃើញប្រកាសលេខ ១៩៨ សអយ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ២០០៨ ស្ដីពីបទដ្ឋានអប្បបរមាសំរាប់ការថែទាំជំនួស ចំពោះកុមារក្នុងសហគមន៍
- បានពិនិត្យការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១ :** បង្កើតការិយាល័យអធិការកិច្ចការថែទាំជំនួសចំពោះកុមារ ស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានសុខុមាលភាពកុមារ នៃអគ្គនាយកដ្ឋានបច្ចេកទេស ។

**ប្រការ ២ :** ការិយាល័យអធិការកិច្ចការថែទាំជំនួសចំពោះកុមារ មានភារកិច្ច

- ត្រួតពិនិត្យ និង វាយតំលៃការអនុវត្តន៍គោលនយោបាយ និង បទដ្ឋានអប្បបរមា នៃការថែទាំជំនួសចំពោះកុមារ



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726 086